

# ទទួលរងនូវ
# ការបៀតបៀនផ្លូវភេទ?
## ដឹងពីសិទ្ធិរបស់អ្នក

សិស្សនិស្សិតនិងបុគ្គលិកត្រូវបានការពារប្រឆាំងនឹងអំពើបៀតបៀនផ្លូវភេទបង្កឡើងដោយជនណាម្នាក់ នៅក្នុងកម្មវិធី ឬសកម្មភាពណាមួយរបស់សាលា រួមទាំងនៅក្នុងបរិវេណសាលា នៅលើរថយន្តក្រុង ឬនៅក្រៅបរិវេណសាលា ដូចជាដំណើរសិក្សាដែលឧបត្ថម្ភដោយសាលាជាដើម។

## អ្វីទៅជាអំពើបៀតបៀនផ្លូវភេទ?

អំពើបៀតបៀនផ្លូវភេទគឺជាទំនាក់ទំនងឬឥរិយាបទឆ្គាំឆ្គងដែលមានលក្ខណៈផ្លូវភេទនៅពេលដែល៖

- សិស្សនិស្សិតឬនិយោជិកណាម្នាក់ត្រូវបានគេធ្វើឲ្យយល់ឃើញថា ខ្លួនត្រូវតែយល់ព្រមឬទទួលយកទំនាក់ទំនង ឬទង្វើឆ្គាំឆ្គងផ្លូវភេទ ដើម្បីទទួលបានអ្វីមួយជាថ្នូរ ដូចជាឡើងថ្នាក់ ឡើងឋានៈ កន្លែងមួយក្នុងក្រុមកីឡា ឬការសម្រេចណាមួយទាក់ទងនឹងការអប់រំឬការងារ ឬ
- ទង្វើនោះជ្រៀតជ្រែកយ៉ាងខ្លាំងដល់លទ្ធផលសិក្សារបស់សិស្សនិស្សិតណាម្នាក់ ឬបង្កជាការគំរាមកំហែង ឬស្ថានភាពលំបាកខ្លាំងដែលប៉ះពាល់ដល់ការសិក្សា និងការងារ។

## តើខ្ញុំរាយការណ៍អំពីការបៀតបៀនផ្លូវភេទតាមរបៀបណា?

អ្នកអាចរាយការណ៍អំពីការបៀតបៀនផ្លូវភេទប្រាប់បុគ្គលិកសាលាណាម្នាក់ ឬមន្ត្រីទទួលបន្ទុកផ្នែកបៀតបៀនផ្លូវភេទ (Title IX Officer) របស់ស្រុក៖

*ដើម្បីទទួលបានឯកសារស្ដីពីគោលនយោបាយ និងនីតិវិធីទាក់ទងនឹងការបៀតបៀនផ្លូវភេទនៅស្រុករបស់លោកអ្នក សូមទាក់ទងមកកាន់ការិយាល័យរបស់សាលា ឬការិយាល័យស្រុករបស់អ្នក។*

### ឧទាហរណ៍នៃការបៀតបៀនផ្លូវភេ៖

- ការដាក់សម្ពាធលើបុគ្គលណាម្នាក់ដើម្បីសេចក្ដីគាប់ផ្លូវភេទ
- ការប៉ះពាល់ដែលមានលក្ខណៈផ្លូវភេទដោយគ្មានការព្រមព្រៀង
- ការសរសេរនៅតាមទីសាធារណៈដែលមានលក្ខណៈផ្លូវភេទ
- ការចែកចាយអត្ថបទដែលលក្ខណៈផ្លូវភេទយ៉ាងច្បាស់ ដូចជាអ៊ីម៉ែល ឬរូបភាព។
- បង្កើតរឿងកំប្លែង ពាក្យចចាមអារ៉ាម ឬកំណត់សម្គាល់ជាយោបល់ដែលមានលក្ខណៈផ្លូវភេទ។
- អំពើហិង្សាលើរាងកាយ រួមមានការចាប់ រំលោភ និងការបំពានផ្លូវភេទ។

**OSPI Equity and Civil Rights Office**
**360.725.6162**
**equity@k12.wa.us**
**www.k12.wa.us/equity**

Equal Access and Opportunities for Students and Educators
Equity & Civil Rights
PROMOTING EDUCATIONAL EXCELLENCE FOR ALL

SUPERINTENDENT OF PUBLIC INSTRUCTION WASHINGTON

**OSPI និងសាលារដ្ឋថ្នាក់ស្រុក (school district) មិនអាចរើសអើងដោយសំអាងទៅលើ ភេទ ជាតិសាសន៍ ពណ៌ សម្បុរ ជំនឿ សាសនា ជាតិកំណើត ភេទ អាយុ ពិការភាព ស្ថានភាពគ្រួសារ ទំនោរផ្លូវភេទ ការសម្ដែងនិងអត្តសញ្ញាណភេទ អតីតយុទ្ធជនឬឋានៈក្នុងផ្នែកយោធា ឬជនពិការដែលប្រើប្រាស់សេវាសត្វពាហនៈជាមធ្យោបាយ និងត្រូវតែផ្ដល់ភាពស្មើគ្នាចំពោះក្រុមយុវជនទាំងអស់ដែលបានកំណត់។ បើមានសំណួរ ឬការតវ៉ា សូមអញ្ជើញទាក់ទងសាលារដ្ឋថ្នាក់ស្រុក ឬ OSPI's Equity និងCivil Rights Office តាមរយៈ P.O. Box 47200, Olympia, WA 98504 ឬទូរស័ព្ទលេខ (360) 725-6162។**

CAMBODIAN